**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៧ សរណន**

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងប្រសិទ្ធភាពយន្តការ "ច្រកចេញ-ចូលតែមួយ"

ក្នុងស្មារតីសំរួលដល់កិច្ចការវិនិយោគ ដើម្បីបង្កើនប្រៀបឈ្នះ ក្នុងការអូសទាញលំហូរវិនិយោគបរទេស ជាមួយបណ្តាប្រទេសនានាក្នុងតំបន់នោះ កន្លងមករាជរដ្ឋាភិបាលបានសំរេចចេញនូវគោលការណ៍ "ច្រកចេញ-ចូលតែមួយ" នៅ "ក.អ.ក" និងនៅអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដោយមិនតំរូវអោយអ្នកវិនិយោគទៅគោះទ្វារក្រសួង-ស្ថាប័នណាផ្សេងឡើយ ពោលគឺ អ្នកវិនិយោគត្រូវបំពេញបែបបទនៅ "ក.អ.ក" ឬនៅអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ហើយរង់ចាំទទួលការឆ្លើយតបវិញប៉ុណ្ណោះ ។

តាមរយៈការអនុវត្តន៍ជាក់ស្តែង យើងបានទទួលនូវលទ្ធផលជាវិជ្ជមានគួរអោយមោទនភាព ទោះបីនៅមានចំណុចខ្វះខាតនកន្លែងខ្លះៗ ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវតែធ្វើការកែសំរួល និងបំពេញបន្ថែមជាបន្ទាន់ក្តី ។

ក្នុងគោលដៅកែលំអបរិស្ថានវិនិយោគនៅកម្ពុជា អោយកាន់តែមានភាពទាក់ទាញថែមទៀតនោះ រាជរដ្ឋាភិបាលសូមធ្វើសេចក្តីណែនាំ ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម ៖

១- **ការផ្តល់មតិរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ**

- គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវធ្វើការឆ្លើយតបមក "ក.អ.ក" វិញ ចំពោះសំណើសុំការបញ្ជាក់លើសំណើសុំនានារបស់អ្នកវិនិយោគ ក្នុងរយៈពេលមិនលើសពី ០១សប្តាហ៍ បន្ទាប់ពីទទួលបានលិខិតសុំការបញ្ជាក់ពី "ក.អ.ក" (លើកលែងតែការចេញលិខិតយល់ព្រម-ការអនុញ្ញាត-អាជ្ញាប័ណ្ណ ឬបញ្ជីកានានា ដែលត្រូវអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង*កំណត់បង្ហាញ* របស់ ក.អ.ក "គ.វ.ក" សុំមតិលើគោលការណ៍វិនិយោគ ដែលត្រូវឆ្លើយតបក្នុងរយៈពេលមិនលើសពី ០៣ថ្ងៃ នៃថ្ងៃធ្វើការ ដូចធ្លាប់អនុវត្តកន្លងមក ដដែល) ។

- ក្នុងករណីមានការយឺតយ៉ាវក្នុងការឆ្លើយតបនោះ "ក.អ.ក"នឹងចាត់ទុកថា សាមីក្រសួង-ស្ថាប័នពាក់ព័ន្ធ បានឯកភាព ឬយល់ព្រមតាមការសំរេចរបស់"ក.អ.ក"ហើយ ។

## ២- ការផ្តល់ទិដ្ឋាការលើសំណើដីសម្បទានសេដ្ឋកិច្ចក្រោម១,០០០ ហិកតា របស់ខេត្ត-ក្រុង

ដោយអនុលោមតាមខ្លឹមសារអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ និងដើម្បីពង្រឹងការអនុវត្តន៍គោលនយោបាយវិសហមជ្ឈការអោយកាន់តែមានប្រសិទ្ធភាពផងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការឆ្លើយតប ឬផ្តល់ទិដ្ឋាការលើសំណើដីសម្បទានក្រោម១,០០០ហិកតា របស់ខេត្ត-ក្រុង យ៉ាងយូរបំផុតត្រឹមរយៈពេល២៨ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលទទួលសំណើ ព្រោះថា :

- ការផ្តល់ទិដ្ឋាការ គឺគ្រាន់តែជាការត្រួតពិនិត្យឡើងវិញ លើការសំរេចក្នុងក្របខ័ណ្ឌខេត្ត-ក្រុងប៉ុណ្ណោះ សំដៅជៀសវាងការប៉ះពាល់តំបន់ព្រៃការពារ - តំបន់ឧទ្យានជាតិ - តំបន់បំរុងទុក ឬតំបន់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ជូនក្រុមហ៊ុនផ្សេងរួចហើយ ។
- ការផ្តល់ទិដ្ឋាការនេះ មិនទាមទារការចុះសិក្សាឡើងវិញទេ ដោយហេតុថា ក្នុងយន្តការផ្តល់គោលការណ៍ដីសម្បទានសេដ្ឋកិច្ចរបស់ខេត្ត-ក្រុង ក៏មានការចូលរួមពីសំណាក់មន្ត្រីរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋបាលព្រៃឈើ ដែលជាខ្សែបណ្តោយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផងដែរ ។

ផុតរយៈពេលកំណត់ខាងលើ ប្រសិនបើគ្មានការឆ្លើយតបទេនោះ ការពិនិត្យសំរេចផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់ខេត្ត-ក្រុង ត្រូវបានចាត់ទុកថា បានទទួលទិដ្ឋាការជាស្វ័យប្រវត្តិ ពីក្រសួងសកិម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប៉ុន្តែខេត្ត-ក្រុងនីមួយៗ មានភារកិច្ចទទួលខុសត្រូវលើផលវិបាកនានាជាយថាហេតុ ប្រសិនបើការត្រួតពិនិត្យនៅពេលខាងមុខឃើញថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនោះ មានការរំលោភទៅនឹងគោលការណ៍ណែនាំកន្លងមក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារបស់រាជរដ្ឋាភិបាល ។

## ៣- ការចុះកិច្ចសន្យាវិនិយោគ

ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តន៍ រាល់កិច្ចសន្យាដូចជាកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច-កិច្ចសន្យា "BOT" កិច្ចសន្យាវ៉ែជាដើម ដែលត្រូវចុះហត្ថលេខាជាមួយភាគីក្រុមហ៊ុន ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

- សាមីក្រសួងត្រូវរៀបចំសេចក្តីព្រាងកិច្ចសន្យាអោយបានត្រឹមត្រូវ ហើយបញ្ជូនមក"ក.អ.ក" ដាក់ប្រជុំអន្តរក្រសួង មុននឹងដាក់ប្រជុំ"ច្រកចេញ-ចូលតែមួយ"ពិនិត្យកែសំរួល និងផ្តល់មតិសុំការសំរេចពីរាជរដ្ឋាភិបាលអោយបានច្បាស់លាស់ មុននឹងឈានទៅចុះហត្ថលេខា ព្រោះថា កិច្ចសន្យាទាំងនេះមានទំនាក់ទំនងនឹងការងារវិនិយោគ ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ចាំបាច់ត្រូវតែចូលរួម និងអនុវត្ត ។ ក្នុងករណីមានការយឺតយ៉ាវ "ក.អ.ក"អាចរៀបចំជាសេចក្តីព្រាងកិច្ចសន្យាជំនួសក្រសួង-ស្ថាប័នពាក់ព័ន្ធសំរាប់ដាក់ប្រជុំតាមនីតិវិធីខាងលើ ។
- ក្នុងពេលរង់ចាំ កិច្ចសន្យាដែលមានការចូលរួមពិនិត្យផ្តល់មតិពីអន្តរក្រសួង ក្រសួង-ស្ថាប័នទទួលបន្ទុកអាចចុះហត្ថលេខា MOU ជាមួយសាមីក្រុមហ៊ុនជាជំហានដំបូង ចំពោះខ្លឹមសារសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ច ទាំងស្រុងរបស់ខ្លួន ។

## ៤. ការលុបគោលការណ៍វិនិយោគ

រាល់គំរោងវិនិយោគដែលបានទទួលគោលការណ៍អនុញ្ញាតរួចហើយពី "ក.អ.ក" ចាំបាច់ត្រូវឆ្លងការសំរេចឯកភាពជាគោលការណ៍ពី "ក.អ.ក" ជាមុន លើការលុបគោលការណ៍វិនិយោគ ឬលុបកិច្ចសន្យាវិនិយោគនានា ព្រោះថា :

- យន្តការ "ច្រកចេញ-ចូលតែមួយ" មានភារកិច្ចចូលរួមពិនិត្យផ្តល់មតិ ទាំងពេលផ្តល់គោលការណ៍វិនិយោគ ទាំងពេលលុបគោលការណ៍វិនិយោគ ។ ម្យ៉ាងវិញទៀត កិច្ចសន្យាវិនិយោគរវាងក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងសាមីក្រុមហ៊ុន ជាឯកសារមូលដ្ឋាននៃគំរោងវិនិយោគ ។ ដូចនេះ រាល់ការលុបកិច្ចសន្យានានា នឹងមានឥទ្ធិពលអវិជ្ជមានដល់គោលការណ៍វិនិយោគ ដែលបានផ្តល់ជូនសាមីក្រុមហ៊ុនកន្លងមកដោយ "ក.អ.ក" ។
- ក្រុមហ៊ុនវិនិយោគដែលបានចុះបញ្ជីនៅ "ក.អ.ក" ត្រូវបានធានាដោយច្បាប់ស្តីពីវិនិយោគ ។
- ការដោះស្រាយវិវាទ រួមទាំងវិវាទរវាងសាមីក្រសួង និងក្រុមហ៊ុន ចាំបាច់ត្រូវដោះស្រាយតាមមាត្រា២០ នៃច្បាប់ស្តីពីវិនិយោគ សំរាប់ជំហានដំបូង ។
- ការលុបកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬគោលការណ៍វិនិយោគជាឯកតោភាគី ដោយពុំបានឆ្លងនីតិវិធីត្រឹមត្រូវ ជាមូលហេតុ ឬជាការបញ្ជូនសារមួយ ធ្វើអោយអ្នកវិនិយោគបាត់ជំនឿលើបរិស្ថានវិនិយោគនៅកម្ពុជា ហើយចុងក្រោយ ច្បាប់-បទប្បញ្ញត្តិស្តីពីវិនិយោគ ដែលបានបង្កើតអោយមានចំណុចទាក់ទាញនោះ នឹងពុំអាចក្លាយជាកត្តា សំរាប់ស្រូបយកទុនពីខាងក្រៅបានឡើយ ។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ មានភារកិច្ចសហការអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល :</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន "ក.អ.ក"
- គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីអនុវត្ត"
- គ្រប់សមាជិក នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ